# ថ្នាំផ្សះ Antibiotics និងរោគបណ្តាលមកពីមេរោគវីរើស
(ប្រសិនបើលោកអ្នកមានរោគគ្រុនផ្តាសាយធម្មតាឬគ្រុនផ្តាសាយធំ ថ្នាំផ្សះ Antibiotics ពុំមានប្រសិទ្ធភាពសំរាប់លោកអ្នកឡើយ) If You Have a Cold or Flu, Antibiotics Won't Work for You

WUML
9/30/07

អស់លោក-លោកស្រី រដូវរោគគ្រុនផ្តាសាយធំ បានឈានជើងមកដល់ហើយ ហើយប្រសិនបើ អស់លោក-លោកស្រីមានរោគគ្រុនផ្តាសាយប្រភេទនេះ ឬគ្រុនផ្តាសាយធម្មតា ថ្នាំផ្សះ Antibiotics ពុំអាចមានប្រសិទ្ធភាពសំរាប់អស់លោក-លោកស្រី បានឡើយ។

រោគគ្រុនផ្តាសាយធម្មតានិងគ្រុនផ្តាសាយធំ ជារោគដែលបណ្តាលមកពីមេរោគវីរើស។ ការទទួលទានថ្នាំផ្សះ Antibiotics ដូចជាថ្នាំ Penicillin ឬ Tetracycline នៅពេលដែលលោកអ្នកមានរោគបណ្តាលមកពីមេរោគវីរើស អាចធ្វើឲ្យរោគនោះ កាន់តែមានសភាពដុនដាប់ ជាងបានជាសះស្បើយ គ្រាន់បើទៅវិញ។ ដូច្នេះ ជាការមួយចាំបាច់ ដែលលោកអ្នកគួរជ្រាបថា តើពេលណាដែលត្រូវប្រើថ្នាំ Antibiotics និងពេលណាដែលពុំគួរប្រើវា។

នៅពេលណាដែលចាប់ផ្តើមហៀរសំបោរឬកណ្តាស់, រម៉ាស់បំពង់កបន្តិចបន្តួចឬ ឈឺដោយសារ Sinus នោះ លោកអ្នកប្រហែលជាមានរោគគ្រុនផ្តាសាយធម្មតាហើយ។

តើលោកអ្នកជ្រាបទេថា រោគគ្រុនផ្តាសាយធម្មតា, ផ្តាសាយធំ, រោគឈឺបំពង់ករភាគច្រើន, និងរោគរលាកទងសួតយ៉ាងខ្លាំង (Acute Bronchitis) គឺបណ្តាលមកពីមេរោគវីរើសនោះ? ហើយ ម្យ៉ាងទៀត តើលោកអ្នកជ្រាបទេថា ថ្នាំ Antibiotics ពុំអាចជួយកំចាត់មេរោគវីរើសបាននោះឡើយ? មិនត្រឹមតែប៉ុណ្ណោះសោត ការប្រើថ្នាំ Antibiotics នៅពេលមានរោគបណ្តាលមកពីមេរោគវីរើស អាចបណ្តាលឲ្យមានផលវិបត្តិ ច្រើនគុណាសម្បត្តិ។

នៅពេលណាដែលមនុស្សពេញវ័យ ឬក្មេងតូចៗទទួលទានថ្នាំ Antibiotics ដើម្បីព្យាបាលរោគបណ្តាលមកពីមេរោគវីរើស ដូចជារោគគ្រុនផ្តាសាយធម្មតានិងគ្រុនផ្តាសាយធំ អ្នកជម្ងឺទាំងនោះ ពុំបានទទួលការព្យាបាលឲ្យត្រឹមត្រូវ ទៅតាមលក្ខណៈរោគនោះឡើយ។ ក៏រឹតថ្នាំផ្សះ Antibiotics ពុំអាចប្រឆាំងកំចាត់មេរោគវីរើស ធ្វើឲ្យអ្នកជម្ងឺបានធូរស្បើយ, ឬពុំអាចចម្លងមេរោគទៅអ្នកដទៃ នោះបានឡើយ។

ការសមនឹងថ្នាំផ្សះ Antibiotics ជាបញ្ហាមួយដែលមានក្នុងវិស័យសាធារណៈសុខាភិបាលទូទាំងពិភពលោក។ ការសមនឹងថ្នាំផ្សះ Antibiotics កើតឡើង នៅពេលណាដែលមេរោគបាក់តេរី ផ្លាស់ប្តូរកម្លាំង ហើយបណ្តាលឲ្យថ្នាំដែលផលិតឡើងសំរាប់ការពាររោគនោះ ពុំសូវមានប្រសិទ្ធភាព។ ឯការប្រើថ្នាំផ្សះនេះ ដោយពុំត្រឹមត្រូវទៅតាមសេចក្តីត្រូវការ ជាកត្តាមួយបណ្តាលឲ្យមេរោគបាក់តេរីសមនឹងថ្នាំ។ ដូច្នេះ នៅពេលក្រោយ ដែលលោកអ្នកត្រូវការទទួលទានថ្នាំផ្សះ Antibiotics សំរាប់ព្យាបាលរោគដែលបណ្តាលមកពីមេរោគបាក់តេរីនោះ វាប្រហែលពុំអាចមានប្រសិទ្ធភាព បានឡើយ។

ថ្នាំផ្សះ Antibiotics ពុំមែនជាថ្នាំសំរាប់ព្យាបាលរោគគ្រុនផ្តាសាយធម្មតាឬគ្រុនផ្តាសាយធំ នោះឡើយ។ ដូច្នេះការប្រើថ្នាំនេះ សំរាប់រោគគ្រុនផ្តាសាយ, ក្អក, គ្រុនផ្តាសាយធំ, រោគរលាកទងសួតខ្លាំង ដែលហៅថា Acute Bronchitis គឺ៖

- ពុំអាចធ្វើឲ្យជារោគ
- ពុំអាចការពារ កុំឲ្យអ្នកដទៃទៀតឆ្លងរោគ
- ពុំអាចជួយឲ្យអ្នកជម្ងឺបានធូរស្បើយ នោះឡើយ
- ម៉្យាងទៀត វាថែមទាំងអាច ធ្វើឲ្យមានផលវិបាកផ្សេងៗ ទៀតផង។

ដូច្នេះ សូមមេត្តាកុំសុំឲ្យគ្រូពេទ្យចេញវេជ្ជបញ្ជាតិទិញថ្នាំផ្សះ Antibiotics នៅពេលណា ដែលគាត់យល់ថា លោកអ្នកពុំត្រូវការនោះ។ ពីព្រោះវាពុំអាចជួយកំចាត់រោគរបស់លោកអ្នកនោះឡើយ។

សូមមេត្តាកុំទទួលទានថ្នាំនេះ ដើម្បីព្យាបាលរោគដែលបណ្តាលមកពីមេរោគវីរើស ដូចជារោគគ្រុនផ្តាសាយធម្មតា, ក្អក, ឬរោគគ្រុនផ្តាសាយធំ ឲ្យសោះ។

ប៉ុន្តែ ប្រសិនបើ គ្រូពេទ្យចេញវេជ្ជបញ្ជាតិឲ្យលោកអ្នកទទួលទានថ្នាំផ្សះ Antibiotics សូមមេត្តាទទួលទានកុំអាក់ខាន ឬកុំឲ្យទុកថ្នាំនោះ សន្សំសំរាប់លេបនៅពេលឈឺថ្ងៃក្រោយ។ ម៉្យាងទៀត សូមមេត្តាកុំលេបថ្នាំផ្សះ ដែលគ្រូពេទ្យចេញវេជ្ជបញ្ជាតិឲ្យសំរាប់អ្នកដទៃ។ ពីព្រោះថ្នាំនោះប្រហែលជាពុំត្រូវនឹងអាការៈរោគរបស់លោកអ្នកនោះឡើយ។ ការប្រើថ្នាំពុំត្រឹមត្រូវ អាចពន្យាពេលព្យាបាលរោគនោះឲ្យបានជាសះស្បើយ និងនាំឲ្យមេរោគកាន់តែបង្កើតខ្លួនច្រើនឡើង ថែមទៀត។

ដើម្បីការពារកុំឲ្យឆ្លងរោគគ្រុនផ្តាសាយធំ គឺដោយលាងដៃជាមួយសាប៊ូឲ្យបានញឹកញាប់។ នៅពេលដែល គ្រូពេទ្យចេញវេជ្ជបញ្ជាតិឲ្យទិញថ្នាំផ្សះ សូមមេត្តាលេបឲ្យត្រឹមត្រូវទៅតាម កំរិតដែលគ្រូពេទ្យអនុមតិ។ ហើយលេបឲ្យអស់ចំនួនដែលគ្រូពេទ្យកំណត់ឲ្យលេប

ទោះបីជាលោកអ្នកមាន អារម្មណ៍ថា រោគនោះបានគ្រាន់បើហើយ ក៏ដោយ។ ពីព្រោះ ប្រសិនបើលោកអ្នក ឈាប់ឈប់ លេបពេក មេរោគបាក់តេរីខ្លះអាចនៅរស់រានមានជីវិត ហើយអាចធ្វើឲ្យលោកអ្នកថ្លាក់ខ្លួនឈឺ ម្តងទៀតបាន។

ចំពោះពត៌មានបន្ថែម សូមមេត្តាអាន វិបសៃរបស់មជ្ឈមណ្ឌលការពារនិងបង្ក្រាបជម្ងឺនៃសហរដ្ឋ, U.S. Center for Disease Control and Prevention អំពីការជ្រាបអំពីពេលដែលថ្នាំផ្សះអាចមានប្រសិទ្ធភាព, Get Smart: Know When Antibiotics Work  ដែលមានអាសយដ្ឋាន [http://www.cdc.gov/drugresistance/community/](http://www.cdc.gov/drugresistance/community/)។